នស/រកម/០៦០៧/០១៤

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

ច្បាប់នេះមានគោលបំណងដាក់ចេញនូវវិធានការ ដើម្បីប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងការរៀបចំ ចាត់ចែង និងត្រួតពិនិត្យ ការប្រតិបត្តិវិធានការទាំងនោះ ។

**មាត្រា ២.- ដែនអនុវត្ត**

ច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀតសម្រាប់ប្រតិបត្តិច្បាប់នេះ ត្រូវអនុវត្តសម្រាប់ទប់ស្កាត់ និងត្រួតពិនិត្យការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**មាត្រា ៣.- និយមន័យនៃពាក្យបច្ចេកទេស**

ក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ពាក្យថា :

ក-**ការសំអាតប្រាក់** គឺជា :

១-ការបំប្លែង ឬ ការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើស ក្នុងគោលបំណងបិទបាំង ឬ ក្លែងប្រភពដើម មិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬ ជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់ នូវសកម្មភាពរបស់ខ្លួន ។

២-ការបិទបាំង ឬ ការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា ឬ កម្មសិទ្ធិ ឬ សិទ្ធិ លើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស ។

៣-ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស ។

៤-ការចូលរួម ការប៉ុនប៉ងប្រព្រឹត្ត ដោយជួយ និង ជម្រុញឱ្យប្រព្រឹត្តសកម្មភាពណាមួយ ដែលបានកំណត់ស្របតាមមាត្រា ៣ នៃច្បាប់នេះ ។

ខ-**ផលនៃបទល្មើស** គឺជាទ្រព្យសម្បត្តិណាដែលបាន ឬ ទទួលដោយផ្ទាល់ ឬ ដោយប្រយោល តាមរយៈការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ បទល្មើសមជ្ឈិម ។

ROYAUME du CAMBODGE LE MINISTRE du PALAIS ROYAL

គ-**ទ្រព្យសម្បត្តិ** គឺជាទ្រព្យគ្រប់ប្រភេទ ចលនទ្រព្យ ឬ អចលនទ្រព្យ រូបិយ ឬ អរូបិយ និងឯកសារ ឬ ឧបករណ៍គតិយុត្តិ ដែលជាភស្តុតាងនៃកម្មសិទ្ធិ ឬ អត្ថប្រយោជន៍លើទ្រព្យទាំងនេះ ។

ឃ-**ស្ថាប័នត្រួតពិនិត្យ** គឺជាធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រ និង ស្ថាប័នផ្សេងទៀត ដែលត្រួតពិនិត្យលើបុគ្គលរាយការណ៍ ។

ង-**សំអាងនៃបទល្មើស** គឺជាបទល្មើសឧក្រិដ្ឋ ឬ បទល្មើសមជ្ឈិម ទោះជាបានប្រព្រឹត្តនៅក្រៅប្រទេស ដែលផលទទួលបានពីបទល្មើសទាំងនេះ អាចក្លាយជាកម្មវត្ថុនៃការសំអាតប្រាក់ដូចបានកំណត់នៅក្នុងកថាខណ្ឌ ក នៃមាត្រា ៣ នៃច្បាប់នេះ ។

ដើម្បីអាចយកមកប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ប្តឹងអំពីការសំអាតប្រាក់ សំអាងនៃបទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្រៅប្រទេស ត្រូវមានចរិតជាបទល្មើសនៅក្នុងប្រទេស ដែលបទល្មើសនេះត្រូវបានប្រព្រឹត្ត និងស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានកិច្ចព្រមព្រៀងពិសេសផ្សេងពីនេះ ។

ច-**ហិរញ្ញប្បទានភេរវកម្ម** គឺជាការផ្តល់ដោយចេតនានូវសេវាហិរញ្ញវត្ថុ ឬសេវាផ្សេងទៀត ក្នុងបំណងប្រើប្រាស់សេវានេះ ឬ ដោយដឹងថាមូលនិធិនេះនឹងត្រូវបាន ឬ អាចប្រើទាំងមូល ឬ មួយផ្នែកសម្រាប់គាំទ្រ ភេរវកម្ម សកម្មភាពរបស់ភេរវករ ឬ អង្គការចាត់តាំងរបស់ភេរវកម្ម ។

ឆ-**ប្រតិបត្តិការសង្ស័យ** គឺជាប្រតិបត្តិការទាក់ទងទៅនឹងមូលនិធិ ដែលត្រូវបានសង្ស័យថាបានមកពីការប្រព្រឹត្តបទល្មើស ឬ ជាមូលនិធិទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម ។

ជ-**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ** គឺជាអង្គការកណ្តាលដែលទទួលខុសត្រូវក្នុងការទទួលវិភាគ និងផ្សព្វផ្សាយរបាយការណ៍ស្តីពីប្រតិបត្តិការសង្ស័យ ដូចបានកំណត់នៅក្នុងកថាខណ្ឌ ឆ នៃមាត្រា ៣ នៃច្បាប់នេះ ប្រតិបត្តិការសាច់ប្រាក់ដូចបានកំណត់នៅក្នុងកថាខណ្ឌ ១ នៃមាត្រា ១២ នៃច្បាប់នេះ និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ។

ឈ-**អត្ថគាហកចុងក្រោយ** គឺជាបុគ្គលដែលកាន់កាប់ ឬ ត្រួតត្រាចុងក្រោយបង្អស់លើអតិថិជន និង/ឬ បុគ្គលដែលធ្វើប្រតិបត្តិការជំនួស រាប់បញ្ចូលទាំងបុគ្គលទាំងឡាយដែលកំពុងធ្វើប្រតិបត្តិការជាចុងក្រោយលើនីតិបុគ្គល ឬ កិច្ចសម្របសម្រួលណាមួយ ។

ញ-**បុគ្គលពាក់ព័ន្ធនយោបាយ** គឺជាឯកត្តជនដែលជា ឬ ដែលត្រូវបានប្រគល់មុខងារសាធារណៈ ខ្ពង់ខ្ពស់នៅក្រៅប្រទេស ដូចជាប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល អ្នកនយោបាយជាន់ខ្ពស់ មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ មន្ត្រីយោធា ឬ មន្ត្រីយុត្តិធម៌ នាយកប្រតិបត្តិជាន់ខ្ពស់នៃសាជីវកម្មរដ្ឋ ឬ មន្ត្រីគណបក្សសំខាន់ៗ ។

ដ-**ក្រុមហ៊ុនអាណត្តិព្យាបាល** គឺជានីតិបុគ្គល ដែលត្រូវបានបង្កើតឡើងដោយបុគ្គលម្នាក់ដែលជាអ្នកប្រគល់អាណត្តិព្យាបាល ។ អ្នកប្រគល់អាណត្តិព្យាបាលផ្ទេរកម្មសិទ្ធិស្របច្បាប់នៃទ្រព្យសម្បត្តិទៅឱ្យអ្នកទទួលអាណត្តិព្យាបាល ដែលធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិនោះ សំរាប់ជាផលប្រយោជន៍ដល់អត្ថគាហកណាម្នាក់ច្បាស់លាស់ ។

ឋ-**ទុច្ចរិតកម្ម** គឺការធ្វើឱ្យទៅជាមោឃៈ ។

## ជំពូកទី ២

## បុគ្គលរាយការណ៍

**មាត្រា ៤.- បុគ្គល និងវិជ្ជាជីវៈចំណុះច្បាប់នេះ**

ច្បាប់នេះត្រូវអនុវត្តចំពោះបុគ្គល និង វិជ្ជាជីវៈដូចខាងក្រោម តទៅនេះហៅថាបុគ្គលរាយការណ៍ ។

ក-ធនាគារ រួមទាំងសាខារបស់ធនាគារបរទេស

ខ-គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ រួមមានក្រុមហ៊ុនជើងសារមូលបត្រនិងក្រុមហ៊ុនធានារ៉ាប់រង

គ-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឃ-សហករណ៍ឥណទាន

ង-ក្រុមហ៊ុនភតិសន្យា មូលនិធិសោធននិងវិនិយោគ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិនិយោគ

ច-អាជីវកម្មប្តូរប្រាក់

ឆ-សេវាផ្ទេរប្រាក់

ជ-ភ្នាក់ងារអចលនទ្រព្យ អគារ និង ដីធ្លី

ឈ-ឈ្មួញលោហធាតុ ត្បូងថ្មមានតម្លៃ

ញ-ការិយាល័យប្រៃសណីយ៍ ដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់

ដ-មេធាវី សារការី គណនេយ្យករ សវនករ ទីប្រឹក្សាវិនិយោគ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ នៅពេលដែលអ្នកទាំងនោះរៀបចំ ឬ ធ្វើប្រតិបត្តិការទាក់ទងទៅនឹងសកម្មភាពបម្រើឱ្យអតិថិជនរបស់ខ្លួនដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ

ឋ-កាស៊ីណូ និង គ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ

ឌ-អង្គការក្រៅរដ្ឋាភិបាល និង អង្គការមូលនិធិ ធ្វើសកម្មភាពអាជីវកម្មនិងរៃអង្គាសមូលនិធិ

ឍ-បុគ្គល ឬវិជ្ជាជីវៈផ្សេងទៀត កំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដែលត្រូវស្ថិតក្នុងដែនអនុវត្តនៃច្បាប់នេះ ។

**មាត្រា ៥.- សកម្មភាពអាជីវកម្មនៃបុគ្គលរាយការណ៍**

សកម្មភាពអាជីវកម្មនៃបុគ្គលរាយការណ៍ ដូចមាននៅក្នុងមាត្រា ៤-ដ នៃច្បាប់នេះ រួមមាន :

១-ការទិញ និង លក់អចលនទ្រព្យ អគារនិងដីធ្លី

២-ការគ្រប់គ្រងប្រាក់ មូលបត្រ ឬ ទ្រព្យសកម្មផ្សេងទៀតរបស់អតិថិជនដូចជា :

ក-ការគ្រប់គ្រងគណនីធនាគារ ឬ គណនីមូលបត្រ

ខ-ការចូលរួមចំណែកក្នុងការបង្កើតប្រតិបត្តិការ ឬ គ្រប់គ្រងក្រុមហ៊ុន

៣-ការបង្កើតប្រតិបត្តិការ ឬ គ្រប់គ្រងនីតិបុគ្គលឬកិច្ចសម្របសម្រួល និងការទិញនិងលក់អង្គភាពអាជីវកម្ម

៤-ក្រុមហ៊ុនអាណត្តិព្យាបាល ឬ ក្រុមហ៊ុនដែលផ្តល់សេវានៅពេលដែលក្រុមហ៊ុនទាំងនោះត្រៀមអនុវត្ត ឬ អនុវត្តសម្រាប់អតិថិជនទាក់ទងនឹងសកម្មភាពទាំងឡាយដូចខាងក្រោម :

-ធ្វើសកម្មភាពជាភ្នាក់ងារបង្កើតនីតិបុគ្គលនោះ

-ធ្វើសកម្មភាព ឬ រៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាព ជានាយក ឬ ជាលេខាធិការរបស់ក្រុមហ៊ុន ជាអ្នកចូលហ៊ុននៃក្រុមហ៊ុនសហកម្មសិទ្ធិ ឬ តួនាទីប្រហាក់ប្រហែលទាក់ទងជាមួយនីតិបុគ្គលផ្សេងទៀត

-ផ្តល់ទីស្នាក់ការផ្លូវការ អាសយដ្ឋាន ឬ ទីតាំងអាជីវកម្ម អាសយដ្ឋានទំនាក់ទំនង ឬ រដ្ឋបាល សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គល ដទៃទៀត ឬ ការសម្របសម្រួលដទៃទៀត

-ធ្វើសកម្មភាព ឬ រៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាព ជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនអាណត្តិព្យាបាល

-ធ្វើសកម្មភាព ឬ រៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាព ជាភាគទុនិកដែលត្រូវបានតែងតាំងជំនួសឱ្យបុគ្គលដទៃ ។

## ជំពូកទី ៣

## វិធានការត្រូវប្រកាន់យកដោយគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ មុខរបរហិរញ្ញវត្ថុមិនមែនធនាគារ និង វិជ្ជាជីវៈដើម្បីទប់ស្កាត់ ការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម

**មាត្រា ៦.- ការសម្ងាត់ធនាគារនិងវិជ្ជាជីវៈ**

ការសម្ងាត់ធនាគារ ឬ វិជ្ជាជីវៈ មិនត្រូវរារាំងការអនុវត្តច្បាប់នេះ និង មិនអាចយកមកប្រើធ្វើលេសអាង ដើម្បីបដិសេធការផ្តល់ព័ត៌មាន ដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងស្ថាប័ន

ត្រួតពិនិត្យ ទោះបីសម្រាប់គោលបំណងសហប្រតិបត្តិការក្នុងប្រទេស ឬ អន្តរជាតិ ឬ ក៏ដូចដែលបានតម្រូវក្នុងការស៊ើបអង្កេតពាក់ព័ន្ធដល់ការសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្មដែលត្រូវបានបញ្ជាដោយ ឬ អនុវត្តក្រោមការត្រួតពិនិត្យរបស់តុលាការ ។

**មាត្រា ៧.- ការហាមឃាត់គណនីអនាមិក ឬ ផលិតផលសនិស**

បុគ្គលរាយការណ៍មិនត្រូវ ៖

ក-បើក ឬ រក្សាទុកគណនីអនាមិក ឬ គណនីដែលមានតែលេខ ឬ គណនីដែលដាក់ឈ្មោះបតិប្អកម្ម

ខ-ចេញផ្សាយ រក្សាទុក ឬ ទទួលយកផលិតផលហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែបានអនុវត្តវិធានការយកចិត្តទុកដាក់ចំពោះអតិថិជនស្របតាមមាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ៨.- វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន**

១-បុគ្គលរាយការណ៍នៅក្នុងមាត្រា ៤ នៃច្បាប់នេះ ត្រូវប្រកាន់យកវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ខ្លួនឱ្យបានច្បាស់លាស់រួមមានការកំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណជាដើមដូចជា ៖

ក-មុនពេលបង្កើតទំនាក់ទំនងអាជីវកម្ម ដូចជាការបើកគណនី ការទទួលថែ-រក្សាភាគហ៊ុន សញ្ញាប័ណ្ណ ឬ មូលបត្រផ្សេងៗក្នុងទូសុវត្ថិភាព ការផ្តល់សេវាប្រអប់សុវត្ថិភាព ឬការចូលរួមប្រកបអាជីវកម្មផ្សេងទៀតជាមួយគ្នា

ខ-មុនពេលអនុវត្តប្រតិបត្តិការមួយដងមួយកាល ឬ តែមួយដង រួមមានការផ្ទេរប្រាក់តាមអេឡិចត្រូនិក ដែលមានចំនួនលើសពីចំនួនកំណត់ដោយស្ថាប័នត្រួតពិនិត្យ ព័ត៌-មានដែលភ្ជាប់មកជាមួយត្រូវមានបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់អ្នកផ្ដើមប្រតិបត្តិការ និងទីកន្លែងដែលគណនីត្រូវបានបើក និងលេខគណនី ។ ក្នុងករណីគ្មានគណនី ត្រូវដាក់តែលេខយោង ។

គ-បើបុគ្គលរាយការណ៍មានការសង្ស័យពីការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយមិនគិតពីបរិមាណប្រាក់នៃប្រតិបត្តិការ

ឃ-បើបុគ្គលរាយការណ៍មានការសង្ស័យអំពីភាពស្មោះត្រង់ ឬ ភាពគ្រប់គ្រាន់

លើទិន្នន័យនៃអត្តសញ្ញាណរបស់អតិថិជន ដែលបានទទួលពីមុនមកហើយ ។

២-បុគ្គលរាយការណ៍ ត្រូវចាត់វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនដូចខាងក្រោម :

ក-សម្គាល់អត្តសញ្ញាណរបស់អតិថិជន ដោយទទួលបានជាអប្បបរមានូវនាម នាមត្រកូល ថ្ងៃ-ខែ-ឆ្នាំកំណើត និងអាសយដ្ឋាន សម្រាប់រូបវន្តបុគ្គល និងនាមករណ៍ លក្ខន្តិកៈ ឬ ការចុះបញ្ជី លេខសម្គាល់ ប័ណ្ណបង់ពន្ធ អាសយដ្ឋាន លេខទូរស័ព្ទជាដើម សម្រាប់នីតិបុគ្គលដូចបានកំណត់ដោយស្ថាប័នត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ថាអតិថិជនបានប្រើប្រាស់ឯកសារ ទិន្នន័យ ឬ ព័ត៌មាន ដែលមានប្រភពឯករាជ្យ គួរឱ្យជឿទុកចិត្តបានក្នុងការផ្តល់អត្តសញ្ញាណរបស់ខ្លួនដូចជាអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងឯកសារ អត្តសញ្ញាណផ្លូវការមានរូបថត

ខ-សម្គាល់អត្តសញ្ញាណអ្នកទទួលប្រាក់ចុងក្រោយ និង ចាត់វិធានការសមស្រប ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណអត្តគាហក តាមវិធីដែលគ្រឹះស្ថានហិរញ្ញវត្ថុបានប្រាកដក្នុងចិត្តថា អ្នកទទួលប្រាក់ចុងក្រោយ ត្រូវបានស្គាល់ច្បាស់លាស់ ។ សម្រាប់នីតិបុគ្គលឬកិច្ចសម្របសម្រួល បុគ្គលរាយការណ៍ ត្រូវចាត់វិធានការសមស្របដើម្បីស្វែងយល់ពីម្ចាស់ និង រចនាសម្ព័ន្ធអភិបាលរបស់អតិថិជន

គ-ទទួលព័ត៌មានពីគោលបំណង និង ប្រភេទនៃទំនាក់ទំនងអាជីវកម្ម

ឃ-បន្តយកចិត្តទុកដាក់ទៅលើទំនាក់ទំនងអាជីវកម្ម និង ពិនិត្យពិច័យប្រតិបត្តិការទាំងឡាយ ដែលបានប្រព្រឹត្តទៅក្នុងពេលទំនាក់ទំនងនេះ ដើម្បីធានាថាប្រតិបត្តិការទាំងនេះ ស្របទៅតាមគោលការណ៍ស្គាល់អតិថិជន មុខរបរនិងទ្រង់ទ្រាយហានិភ័យរបស់បុគ្គលរាយការណ៍ទាំងនោះ រួមទាំងប្រភពមូលនិធិផងបើចាំបាច់ ។

៣-នៅពេលណាបុគ្គលរាយការណ៍ មិនអាចអនុវត្តតាមកថាខណ្ឌ ២-ក ដល់ គ នៃមាត្រានេះ បុគ្គលនោះមិនត្រូវបើកគណនី មិនត្រូវចាប់ផ្តើមទំនាក់ទំនងអាជីវកម្ម ឬអនុវត្តប្រតិបត្តិការ ឬ ក្នុងករណីមានទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនរួចហើយ ត្រូវបញ្ចប់ទំនាក់ទំនងអាជីវកម្មនោះ លើកលែងតែមានការណែនាំផ្ទុយពីនេះ ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។ ក្នុងករណីដូចនេះ បុគ្គលរាយការណ៍ត្រូវពិចារណាពីការធ្វើរបាយការណ៍ស្តីពីប្រតិបត្តិការសង្ស័យទាក់ទងជាមួយអតិថិជននោះ ។

៤-កាតព្វកិច្ចដែលមានចែងក្នុងមាត្រានេះ ត្រូវអនុវត្តចំពោះអតិថិជនថ្មីទាំងអស់ ក៏ដូចជាអតិថិជនដែលមានស្រាប់ ផ្អែកលើមូលដ្ឋាននៃការពិត និង ហានិភ័យ ។ បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ពិនិត្យឡើងវិញ ចំពោះទំនាក់ទំនងដែលមានស្រាប់ ។

**មាត្រា ៩.- ការសម្គាល់អត្តសញ្ញាណអតិថិជន ដែលធ្វើប្រតិបត្តិការក្រោមកម្រិតកំណត់**

ការសម្គាល់អត្តសញ្ញាណ ក៏ត្រូវអនុវត្តផងដែរ ក្នុងករណីប្រតិបត្តិការដាច់ៗពីគ្នាត្រូវបានធ្វើជាច្រើនដង ដោយប្រតិបត្តិការនីមួយៗមានចំនួនប្រាក់តិចជាងចំនួនដែលបានកំណត់ដោយស្ថាប័នត្រួតពិនិត្យ ប៉ុន្តែបុគ្គលរាយការណ៍មានហេតុផលដែលអាចជឿបានថា ប្រតិបត្តិការទាំងនោះ ត្រូវបានធ្វើឡើងក្នុងគោលបំណងចៀសវាងការសម្គាល់អត្តសញ្ញាណ ។

**មាត្រា ១០.- ការតាមដានត្រួតពិនិត្យពិសេសទៅលើប្រតិបត្តិការមួយចំនួន**

១-បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ ជាពិសេសលើ :

ក-ប្រតិបត្តិការណាដែលស្មុគ្រស្មាញ មិនប្រក្រតី ឬ មានចំនួនប្រាក់ច្រើន

ខ-ប្រភេទប្រតិបត្តិការមិនប្រក្រតី ដែលមិនបង្ហាញពីគោលបំណងសេដ្ឋកិច្ច ឬ ស្របច្បាប់ច្បាស់លាស់ណាមួយ

គ-ទំនាក់ទំនងអាជីវកម្ម និង ប្រតិបត្តិការជាមួយគ្រឹះស្ថាន ឬ បុគ្គលក្នុងយុត្តាធិការដែលមិនមានប្រព័ន្ធគ្រប់គ្រាន់ សម្រាប់បង្ការ ឬ រារាំងសកម្មភាពសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម

ឃ-ការផ្ទេរប្រាក់តាមអេឡិចត្រូនិក ដែលពុំមានព័ត៌មានរបស់អ្នកផ្តើមប្រតិបត្តិការគ្រប់គ្រាន់

ង-ទំនាក់ទំនងអាជីវកម្ម និង ប្រតិបត្តិការជាមួយបុគ្គលណា ដែលបុគ្គលរាយការណ៍មិនបានជួបប្រាស្រ័យផ្ទាល់នៅពេលអនុវត្តនីតិវិធីសម្គាល់អត្តសញ្ញាណ

ច-ទំនាក់ទំនងអាជីវកម្ម និង ប្រតិបត្តិការជាមួយបុគ្គលពាក់ព័ន្ធនយោបាយ

ឆ-ទំនាក់ទំនងអាជីវកម្ម និងប្រតិបត្តិការដែលធ្វើតាមរយៈធនាគារទំនាក់ទំនងឆ្លងដែន ឬ ទំនាក់ទំនងដូចនេះផ្សេងទៀត ។

២-ក្នុងករណីយោងទៅកថាខណ្ឌទី ១ នៃមាត្រានេះ បុគ្គលរាយការណ៍ត្រូវស្វែងរកព័ត៌មានបន្ថែមអំពីប្រភពដើម និងគោលដៅរបស់ប្រាក់ គោលបំណងនៃប្រតិបត្តិការ និង អត្តសញ្ញាណរបស់ភាគីចូលរួមប្រតិបត្តិការ ។

**មាត្រា ១១.- ការរក្សាទុកឯកសារកត់ត្រារបស់បុគ្គលរាយការណ៍**

បុគ្គលរាយការណ៍ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់នេះ ត្រូវរក្សាទុកឯកសារកត់ត្រាអត្តសញ្ញាណ និង ប្រតិបត្តិការរបស់អតិថិជនឱ្យបានគ្រប់គ្រាន់យ៉ាងតិចបំផុតប្រាំ (០៥)ឆ្នាំ ក្រោយគណនីត្រូវបានបិទ ឬ ទំនាក់ទំនងអាជីវកម្ម ជាមួយអតិថិជនត្រូវបានបញ្ចប់ និងត្រូវរក្សាទុកសម្រាប់តម្រូវការរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអាចមើលឡើងវិញនូវប្រតិបត្តិការនីមួយៗ រួមមានចំនួនប្រាក់ និង ប្រភេទរូបិយប័ណ្ណ បើមាន ដើម្បីផ្តល់ភស្តុតាងសមស្រប សម្រាប់កាត់ទោសជនល្មើស ។

**មាត្រា ១២.- របាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ ឬ ប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ**

១-បុគ្គលរាយការណ៍ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់នេះ ត្រូវរាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនូវប្រតិបត្តិការសាច់ប្រាក់ ដែលលើសពីចំនួនកំណត់ដោយស្ថាប័នត្រួតពិនិត្យ ក៏ដូចជាប្រតិបត្តិការណាដែលពាក់ព័ន្ធប្រតិបត្តិការសាច់ប្រាក់ច្រើនដង ហើយចំនួនប្រាក់សរុបលើសពីចំនួនដែលបានកំណត់នេះ ។

២-ដោយពុំគិតដល់កាតព្វកិច្ចរាយការណ៍ ដែលបានកំណត់នៅកថាខណ្ឌទី ១ នៃមាត្រានេះ បើបុគ្គលរាយការណ៍សង្ស័យ ឬ មានមូលដ្ឋានសមស្រប ដើម្បីសង្ស័យថាមូលនិធិជាផលបានមកពីការប្រព្រឹត្តបទល្មើស ឬ ជាប់ទាក់ទងដល់ហិរញ្ញប្បទានភេរវកម្ម បុគ្គលរាយការណ៍ត្រូវរាយការណ៍ជាបន្ទាន់ក្នុងរយៈពេល ២៤ ម៉ោង ពីការសង្ស័យរបស់ខ្លួនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

៣-របាយការណ៍ពីការសង្ស័យ ត្រូវបញ្ជូនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ តាមមធ្យោបាយទំនាក់ទំនងឆាប់រហ័សណាមួយ ដូចជាទូរសារ ឬ ប្រសិនបើគ្មាន តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ។ របាយការណ៍តាមទូរស័ព្ទ ត្រូវបញ្ជាក់បន្ថែមតាមទូរសារ ឬ លិខិតជាលាយ-

លក្ខណ៍អក្សរក្នុងរយៈពេលមួយខ្លីបំផុតដែលអាចធ្វើបាន ។ នៅពេលទទួលបានរបាយការណ៍ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវបញ្ជាក់ថាបានទទួល ។

៤-បុគ្គលរាយការណ៍ ដែលបានធ្វើរបាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក៏ដូចជាស្ថាប័នផ្សេងទៀត ដែលមានព័ត៌មានទាក់ទងដល់ប្រតិបត្តិការ ឬ ដល់អតិថិជនដែលជាប់ពាក់ព័ន្ធនៅក្នុងរបាយការណ៍ ត្រូវផ្តល់ឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ឬ ស្ថាប័នអនុវត្តច្បាប់ដែលកំពុងស៊ើបអង្កេត ដោយផ្តើមចេញពី ឬ ទាក់ទងដល់ព័ត៌មាននៅក្នុងរបាយការណ៍ និងព័ត៌មានផ្សេងទៀត ដែលមានអំពីប្រតិបត្តិការ ឬ ប្រតិបត្តិការដែលត្រូវបានប៉ុនប៉ងធ្វើ ឬ ភាគីចូលរួមក្នុងប្រតិបត្តិការ បើមានការស្នើសុំពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ឬ ស្ថាប័នអនុវត្តច្បាប់ ។

៥-បើអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ មានមូលដ្ឋានសមហេតុផលក្នុងការសង្ស័យថាប្រតិបត្តិការ ឬ សំណើប្រតិបត្តិការមួយ អាចជាប់ពាក់ព័ន្ធបទល្មើសសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ឬ សម្រាប់ករណីប្រាកដប្រជា ឬ បន្ទាន់ បើយល់ថាចាំបាច់ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ អាចណែនាំបុគ្គលរាយការណ៍ជាលាយលក្ខណ៍អក្សរ ឬ តាមទូរស័ព្ទ បន្ទាប់មកជាលាយលក្ខណ៍អក្សរមិនឱ្យបន្តដំណើរការប្រតិបត្តិការនោះ ឬ ប្រតិបត្តិការដែលបានធ្វើ ឬប្រតិបត្តិការផ្សេងណា ដែលមានមូលនិធិទាក់ទងដល់ប្រតិបត្តិការនោះ ឬ ប្រតិបត្តិការដែលបានស្នើក្នុងរយៈពេលមួយដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបានកំណត់មិនឱ្យលើសពី ៤៨ ម៉ោង ដើម្បីឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាច ៖

-ធ្វើការស៊ើបអង្កេតចាំបាច់អំពីប្រតិបត្តិការ

-ផ្តល់ព័ត៌មាន និង ផ្តល់យោបល់ទៅស្ថាប័នអនុវត្តច្បាប់ បើយល់ថា សមស្រប ។

**មាត្រា ១៣.- ខ្លឹមសារនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ**

របាយការណ៍ប្រតិបត្តិការសង្ស័យ ដែលត្រូវបានធ្វើទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានភ្ជាប់មកជាមួយជាអប្បបរមានូវ ៖

ក-អត្តសញ្ញាណ និង សញ្ញាណសម្គាល់របស់បុគ្គលរាយការណ៍ រួមទាំងឈ្មោះ និងព័ត៌មានលំអិតសម្រាប់ទាក់ទងនៃមន្ត្រីរាយការណ៍

ខ-អត្តសញ្ញាណ និង សញ្ញាណសម្គាល់របស់អតិថិជននិងអត្ថគាហក ដែលពាក់ព័ន្ធក្នុងប្រតិបត្តិការនោះ

គ-ប្រភេទ និង ព័ត៌មានលំអិតនៃប្រតិបត្តិការ ដូចជាចំនួនប្រាក់ រូបិយប័ណ្ណ កាលបរិច្ឆេទ ភាគីពាក់ព័ន្ធដែលត្រូវបានរាយការណ៍ថាសង្ស័យ រួមមានលេខគណនី សញ្ញាណសម្គាល់របស់ម្ចាស់គណនីនោះ

ឃ-ពិពណ៌នាដោយសង្ខេបពីកាលៈទេសៈ និង ហេតុផលផ្សេងៗ ដែលបង្ហាញឱ្យឃើញថាជាប្រតិបត្តិការសង្ស័យ ។

**មាត្រា ១៤.- ការរួចផុតពីការទទួលខុសត្រូវចំពោះការរាយការណ៍ដោយសុចរិតនូវប្រតិបត្តិការសាច់ប្រាក់ ឬ ប្រតិបត្តិការសង្ស័យ**

បុគ្គល នាយក ឬ និយោជិតរបស់បុគ្គលរាយការណ៍ :

១-ដែលបានបញ្ជូនព័ត៌មាន ឬ ធ្វើរបាយការណ៍ ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដោយសុចរិត ស្របតាមច្បាប់នេះ មិនត្រូវបានប្តឹងចោទប្រកាន់ណាមួយពីបទរំលោភលើការហាមឃាត់ ក្នុងការបើកចំហព័ត៌មាន ឬ ការសម្ងាត់ធនាគារ ឬ ការសម្ងាត់វិជ្ជាជីវៈឡើយ ។

២-ដែលបានបញ្ជូនព័ត៌មាន ឬ ធ្វើរបាយការណ៍ដោយសុចរិតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ មិនត្រូវបានតម្រូវឱ្យទទួលខុសត្រូវពីផ្នែករដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌក៏ដូចជាមិនត្រូវទទួលទណ្ឌកម្មខាងវិជ្ជាជីវៈណាមួយឡើយ ទោះបីជាមានការស៊ើបអង្កេត ក៏មិនអាចនាំទៅដល់ការផ្តន្ទាទោសដែរ ។

៣-មិនត្រូវបានតម្រូវឱ្យទទួលខុសត្រូវពីផ្នែករដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ ដោយហេតុផលថា បានបង្កការខាតបង់ណាមួយខាងសម្ភារៈ និង/ឬ មិនមែនសម្ភារៈ កើតឡើងដោយសារការព្យួរប្រតិបត្តិការដូចមានចែងនៅកថាខណ្ឌ ៥ មាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ១៥.- ការហាមឃាត់ការផ្តល់ព័ត៌មាន**

ក្នុងកាលៈទេសៈណាក៏ដោយ បុគ្គលដែលមានកាតព្វកិច្ចផ្តល់ព័ត៌មាន ឬ បញ្ជូនរបាយការណ៍ដូចមានចែងនៅក្នុងមាត្រា ១៣ ឬ បុគ្គលណាដែលបានដឹងរឿង មិនត្រូវផ្តល់ព័ត៌មាន

ឬ រាយការណ៍ទាំងនោះទៅបុគ្គលផ្សេង ក្រៅពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុទេ លើកលែងតែមានការអនុញ្ញាតពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

**មាត្រា ១៦.- ការត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាមរបស់បុគ្គលរាយការណ៍**

បុគ្គលរាយការណ៍ ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ ត្រូវបង្កើតកម្មវិធីសម្រាប់ទប់ស្កាត់ការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម តាមការណែនាំរបស់ស្ថាប័នត្រួតពិនិត្យ ដូចមានចែងក្នុងមាត្រា ៣១ នៃច្បាប់នេះ ។ កម្មវិធីទាំងនេះរួមមាន :

ក-ការបង្កើតគោលនយោបាយ នីតិវិធី និង ការត្រួតពិនិត្យផ្ទៃក្នុង រួមមានការរៀបចំការប្រតិបត្តិឱ្យបានសមស្រប និង នីតិវិធីតាមដានគ្រប់គ្រាន់ ដើម្បីធានាឱ្យមានលក្ខណសម្បត្តិខ្ពស់នៅពេលជ្រើសរើសនិយោជិត

ខ-ការតែងតាំងមន្ត្រីប្រតិបត្តិជាមន្ត្រីថ្នាក់គ្រប់គ្រង

គ-ការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកជាប្រចាំ

ឃ-មុខងារត្រួតពិនិត្យផ្ទៃក្នុង ដើម្បីផ្ទៀងផ្ទាត់ការប្រតិបត្តិ និង ប្រសិទ្ធភាពនៃរាល់វិធានការណ៍ ដែលត្រូវប្រកាន់យកដើម្បីអនុវត្តច្បាប់នេះ ។

**មាត្រា ១៧.- មន្ត្រីប្រតិបត្តិ**

មន្ត្រីប្រតិបត្តិដែលត្រូវបានតែងតាំងស្របតាមកថាខណ្ឌ ខ មាត្រា ១៦ នៃច្បាប់នេះ ជាមន្ត្រីជាន់ខ្ពស់មាន គុណវុឌ្ឍិ និងបទពិសោធន៍គ្រប់គ្រាន់ ដែលអាចមានលទ្ធភាពឆ្លើយតបបានល្អត្រឹមត្រូវទៅនឹងសំណួរទាក់ទងជាមួយបុគ្គលរាយការណ៍ និង ដំណើរការអាជីវកម្មរបស់បុគ្គលនោះ ព្រមទាំងអាចទទួលខុសត្រូវជាអប្បបរមា :

ក-ដើម្បីបង្កើត និង ថែរក្សាគោលនយោបាយផ្ទៃក្នុង នីតិវិធី និង សៀវភៅណែនាំពីការប្រតិបត្តិ

ខ-ដើម្បីធានាឱ្យបុគ្គលិករបស់បុគ្គលរាយការណ៍ប្រតិបត្តិបានត្រឹមត្រូវតាមបទ-

ROYAUME DU CAMBODGE · LE MINISTERE DU PALAIS ROYAL ·

ក្រសួងព្រះបរមរាជវាំង

ua

15/24..

ប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតដែលទាក់ទងដល់ការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម និងបទប្បញ្ញត្តិនៃគោលនយោបាយ នីតិវិធី និង សៀវភៅណែនាំពីការប្រតិបត្តិដែលបានបង្កើតឡើងស្របតាមមាត្រានេះ

គ-ដើរតួជាអ្នកទំនាក់ទំនងរវាងបុគ្គលរាយការណ៍ និង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក្នុងការងារ ដែលទាក់ទងដល់ការប្រតិបត្តិបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ផ្សេងទៀត ដែលចែងអំពីការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**មាត្រា ១៨.– ភាពពុកិច្ចសមស្របនិងត្រឹមត្រូវ**

ស្ថាប័នត្រួតពិនិត្យត្រូវធានាថា គណៈគ្រប់គ្រង និង ភាគទុនិករបស់បុគ្គលរាយការណ៍ មានលក្ខណៈសមស្រប និងត្រឹមត្រូវ ដើម្បីអាចទប់ស្កាត់ឧក្រិដ្ឋជន និងសមាគមមិនឱ្យកាន់កាប់ ឬ ក្លាយជាអត្ថគាហក ឬ ជាអ្នកកាន់កាប់ផលប្រយោជន៍សំខាន់ៗ ឬ មុខងារគ្រប់គ្រងនៅក្នុងអង្គភាពទាំងនោះ ។

## ជំពូកទី ៤
## អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ

**មាត្រា ១៩.– ការរៀបចំ**

១-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវតែបានបង្កើតឡើងជាអង្គភាព ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ។

២-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងអំណាចធ្វើការសម្រេចចិត្តដោយឯករាជ្យក្នុងការងារដែលស្ថិតក្នុងដែននៃការទទួលខុសត្រូវរបស់ខ្លួន ។

**មាត្រា ២០.– បុគ្គលិកនិងក្រុមប្រឹក្សាភិបាល**

១-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយដឹកនាំដោយមន្ត្រីជាន់ខ្ពស់មួយរូបតែងតាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់ធនាគារជាតិនៃកម្ពុជា ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវធ្វើការដោយស្ថិតនៅក្រោមនិវាទរបស់ក្រុមប្រឹក្សាភិបាល ដែលរួមមានមន្ត្រីជាន់ខ្ពស់តំណាងឱ្យស្ថាប័នដូចខាងក្រោម :

6/24.

ក-ទីស្តីការគណៈរដ្ឋមន្ត្រី

ខ-ក្រសួងយុត្តិធម៌

គ-ក្រសួងមហាផ្ទៃ

ឃ-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ង-ធនាគារជាតិនៃកម្ពុជា

២-ប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់ធនាគារជាតិនៃកម្ពុជា ដោយជ្រើសរើសចេញពីតំណាងស្ថាប័នដូចបានរៀបរាប់ខាងលើសម្រាប់រយៈពេលពីរ (០២) ឆ្នាំ ។ ប្រធានអាណត្តិទីមួយរបស់ក្រុមប្រឹក្សាភិបាល ត្រូវតែជាតំណាងធនាគារជាតិនៃកម្ពុជា ។ សមាសភាពក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ធនាគារជាតិនៃកម្ពុជា ។

៣-លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានបុគ្គលិកគ្រប់គ្រាន់ដែលត្រូវជ្រើសរើសដោយប្រធាន និង ត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។ បុគ្គលិកត្រូវមានលក្ខណសម្បត្តិសុចរិតកម្រិតខ្ពស់ និង ត្រូវបានពិនិត្យជ្រើសរើសដោយអាជ្ញាធរពាក់ព័ន្ធ មុននឹងត្រូវបានអនុញ្ញាតឱ្យបម្រើការនៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ។

**មាត្រា ២១.- មុខងារ**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវ :

ក-ទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ ដែលធ្វើឡើងស្របតាមមាត្រា ១២ នៃច្បាប់នេះ និងព័ត៌មានស្តីពីការសង្ស័យនៃការសំអាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានផ្ញើមក

ខ-ប្រមូលព័ត៌មានដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុយល់ថា ទាក់ទងដល់សកម្មភាពរបស់ខ្លួនស្តីពីការសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្ម ហើយដែលមានផ្សព្វផ្សាយជាសាធារណៈ រួមមានទិន្នន័យពាណិជ្ជកម្ម ក៏ដូចជាព័ត៌មានផ្សេងៗទៀតដែលចាំបាច់ សម្រាប់អនុវត្តមុខងាររបស់ខ្លួនដូចជាព័ត៌មានដែលបានប្រមូល និងរក្សាទុកក្នុងទិន្នន័យ ដោយបុគ្គល

LE MINISTRE DU PALAIS ROYAL
ព្រះរាជវាំង

17/24../

../2

គ-យកតាមកាលានុវត្តស្របតាមច្បាប់នូវព័ត៌មានហិរញ្ញវត្ថុ រដ្ឋបាល និងព័ត៌មានសម្រាប់ការពង្រឹង ការអនុវត្តច្បាប់ ដែលចាំបាច់សម្រាប់ការបំពេញមុខងាររបស់ខ្លួនដូចមានចែងក្នុងមាត្រានេះ រួមទាំងព័ត៌មាន ដែលត្រូវបានប្រមូល និងថែរក្សាទុកក្នុងទិន្នន័យរបស់ស្ថាប័នសាធារណៈផ្សេងៗ

ឃ-វិភាគ និង វាយតម្លៃនូវរាល់របាយការណ៍ប្រតិបត្តិការសង្ស័យ និងព័ត៌មានពាក់ព័ន្ធ ដើម្បីកំណត់ពីមូលដ្ឋានសមស្របដែលនាំឱ្យជឿជាក់ថា បទល្មើសសំអាតប្រាក់ ឬបទល្មើសហិរញ្ញប្បទានភេរវកម្មបានកើតឡើង ហើយក្នុងករណីនេះ បញ្ជូនសំណុំរឿងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស៊ើបអង្កេតពីបទល្មើស

ង-ចងក្រងស្ថិតិ និង កត់ត្រាអំពីរបាយការណ៍ប្រតិបត្តិការសង្ស័យ និងសាច់ប្រាក់ដែលបានទទួលវិភាគ និង បញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច និងផ្តល់ព័ត៌មានទាំងនោះទៅស្ថាប័នសាធារណៈផ្សេងទៀត យោងតាមរឿងហេតុដែលពាក់ព័ន្ធ

ច-ផ្តល់មតិទៅបុគ្គលរាយការណ៍ និង ស្ថាប័នពាក់ព័ន្ធផ្សេងៗនូវលទ្ធផលនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ ឬ ព័ត៌មានផ្សេងៗដូចមានចែងនៅក្នុងច្បាប់នេះ

ឆ-ធានាថា រាល់ព័ត៌មានផ្ទាល់ខ្លួនដែលស្ថិតនៅក្នុងដៃរបស់ខ្លួន ត្រូវបានការពារមិនឱ្យបើកចំហដោយគ្មានការអនុញ្ញាត

ជ-ចាត់វិធានការដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីការងារទាក់ទងដល់ការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ។

**មាត្រា ២២.- ការត្រួតពិនិត្យដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ**

១-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវចេញសេចក្តីណែនាំទៅបុគ្គលរាយការណ៍ស្តីពីការសម្គាល់អត្តសញ្ញាណរបស់អតិថិជន ការរក្សាទុកឯកសារកត់ត្រា ការរាយការណ៍ ប្រតិបត្តិការសង្ស័យ និង កាតព្វកិច្ចផ្សេងទៀតស្របតាមច្បាប់នេះ ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវតែត្រួតពិនិត្យ ឬធ្វើជាមួយស្ថាប័នត្រួតពិនិត្យមានសមត្ថកិច្ច ក្នុងករណីដែលការត្រួតពិនិត្យដូចនេះមិនត្រូវបានធ្វើរួចហើយ ។

២-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវធានាពីការប្រតិបត្តិរបស់បុគ្គលរាយការណ៍ស្របតាមកាតព្វកិច្ចនានាដែលចែងក្នុងច្បាប់នេះ តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងស្របតាមច្បាប់ដែលពាក់ព័ន្ធ ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវសម្របសម្រួលការងារត្រួតពិនិត្យការប្រតិបត្តិតាមច្បាប់នេះជាមួយស្ថាប័នត្រួតពិនិត្យដែលមានស្រាប់ ។

៣-ក្នុងពេលត្រួតពិនិត្យ បើរកឃើញការមិនប្រតិបត្តិតាមបទប្បញ្ញត្តិនៃច្បាប់នេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាច :

ក-ណែនាំបុគ្គលរាយការណ៍ឱ្យប្រកាន់យកសកម្មភាពកែតម្រូវ ដូចដែលបានកំណត់

ខ-ជូនព័ត៌មានទៅស្ថាប័នត្រួតពិនិត្យផ្សេងទៀត អំពីការមិនប្រតិបត្តិតាម និងលើកសំណើឱ្យស្ថាប័នទាំងនោះ អនុវត្តវិធានការត្រួតពិនិត្យរួមមានការដាក់ទណ្ឌកម្ម ឬ ការដកហូតអាជ្ញាប័ណ្ណតាមសមត្ថកិច្ចរៀងខ្លួន

គ-ដាក់ទណ្ឌកម្មខាងរដ្ឋបាលស្របតាមច្បាប់នេះ ។

**មាត្រា ២៣.- ភាតព្វកិច្ចរក្សាការសម្ងាត់**

ក្រុមប្រឹក្សាភិបាល និង លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់នៃរាល់ព័ត៌មានដែលទទួលបានក្នុងដែននៃភារកិច្ចរបស់ខ្លួន ទោះបីជាក្រោយពេលចប់ភារកិច្ចនៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុក៏ដោយ ។ រាល់ព័ត៌មានមិនអាចយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេង ក្រៅពីគោលបំណងដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ២៤.- មូលដ្ឋានទិន្នន័យ**

យោងតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការការពារសិទ្ធិឯកជន និង មូលដ្ឋានទិន្នន័យប្រព័ន្ធកុំព្យូទ័រ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវដំណើរការមូលដ្ឋានទិន្នន័យដែលមានព័ត៌មានស្តីពីរបាយការណ៍ប្រតិបត្តិការសង្ស័យ និង ប្រតិបត្តិការសាច់ប្រាក់ដូចដែលបានតម្រូវដោយច្បាប់នេះ ។ ព័ត៌មានទាំងនោះត្រូវតែបានធ្វើបច្ចុប្បន្នកម្ម និង រៀបចំក្នុងន័យដើម្បីធានាប្រសិទ្ធភាព

19/24 ./

ជាអតិបរមានៃការវិភាគប្រតិបត្តិការរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងជួយបញ្ជាក់ថាជាការពិត ឬ ធ្វើឱ្យទុព្វលកម្មការសង្ស័យ ។

**មាត្រា ២៥.- ទំនាក់ទំនងជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស**

១-យោងតាមការសម្របសម្រួលគ្នាទៅវិញទៅមក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាចផ្លាស់ប្តូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសបាន លុះណាតែអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសមានកាតព្វកិច្ចរក្សាការសម្ងាត់ដូចគ្នា ដោយមិនគិតពីប្រភេទនៃអង្គភាពទាំងនោះ ។ សម្រាប់គោលបំណងនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាចចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គភាពទាំងនោះបាន ។

២-នៅពេលបានទទួលសំណើសុំព័ត៌មាន ឬ ការបញ្ជូនព័ត៌មានពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជាដៃគូនៅបរទេស អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុត្រូវឆ្លើយតបតាមសំណើក្នុងដែនអំណាចនៃច្បាប់នេះ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ២៦.- ការសម្របសម្រួលផ្ទៃក្នុង**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ស្ថាប័នអនុវត្តច្បាប់ ស្ថាប័នត្រួតពិនិត្យ ព្រមទាំងស្ថាប័នរាជរដ្ឋាភិបាលមាន សមត្ថកិច្ចផ្សេងទៀតដែលទទួលខុសត្រូវទប់ស្កាត់ ឬ ត្រួតពិនិត្យការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបង្កើតយន្តការអចិន្ត្រៃយ៍កម្រិតខ្ពស់រៀងៗខ្លួនសម្រាប់ :

ក-ធានាអំពីការផ្លាស់ប្តូរព័ត៌មាន និង ការសម្របសម្រួលរវាងអាជ្ញាធរទាំងនេះជាមួយសមាគមឯកជនដែលពាក់ព័ន្ធ

ខ-ផ្តល់ការណែនាំសម្រាប់ការអនុវត្តច្បាប់នេះ

គ-បង្កើតគោលនយោបាយសម្រាប់វិស័យផ្សេងៗ ដែលស្ថិតនៅក្នុងដែនកំណត់នៃការអនុវត្តច្បាប់នេះ ។

មុខងារនិងភារកិច្ចនៃយន្តការសម្របសម្រួលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៧.- ការកម្រិតការប្រើប្រាស់សាច់ប្រាក់ក្នុងប្រតិបត្តិការពាណិជ្ជកម្ម**

រាជរដ្ឋាភិបាលត្រូវមានវិធានការសមស្រប ដើម្បីកាត់បន្ថយចរាចរណ៍ និង ការប្រើប្រាស់សាច់ប្រាក់ក្នុងប្រតិបត្តិការពាណិជ្ជកម្ម និង លើកទឹកចិត្តឱ្យប្រើប្រាស់មធ្យោបាយទូទាត់មិនមែនសាច់ប្រាក់ ដែលជួយសម្រួលដល់ការសម្គាល់អត្តសញ្ញាណរបស់ភាគីដែលចូលរួម ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ២៨.- ទណ្ឌកម្មខាងវិន័យ**

ស្ថាប័នត្រួតពិនិត្យត្រូវដាក់ទណ្ឌកម្មខាងវិន័យ ទៅលើបុគ្គលរាយការណ៍ណាដែលមិនប្រតិបត្តិតាមបទប្បញ្ញត្តិនៃមាត្រា ៧ ដល់មាត្រា ១២ និងមាត្រា ១៦ នៃច្បាប់នេះ ។

ការប្រព្រឹត្តល្មើសដូចមានចែងនៅក្នុងកថាខណ្ឌខាងលើ ត្រូវរងទណ្ឌកម្មដូចខាងក្រោម:

-ការព្រមាន

-ការស្តីបន្ទោស

-ការហាមឃាត់ ឬ ដាក់កំហិតមិនឱ្យធ្វើប្រតិបត្តិការណាមួយ ឬ ក្នុងរយៈពេលមួយតាមការកំណត់របស់ស្ថាប័នត្រួតពិនិត្យ

-ការដកហូតអាជ្ញាប័ណ្ណប្រកបអាជីវកម្ម

-ការស្នើឱ្យដកហូតតំណែងមន្ត្រី ឬ នាយកចាត់ការដែលពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ទាំងនោះ

-ការផាកពិន័យ

-ការបញ្ជាឱ្យឃាត់ទុកជាបណ្តោះអាសន្ននូវមធ្យោបាយ និង លទ្ធផលនៃការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម

-ប្តឹងទៅតុលាការ នៅពេលដែលការរំលោភលើបទប្បញ្ញត្តិនៃច្បាប់នេះ និង បទបញ្ជាទាំងឡាយមានភាពធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណជន និង ឧស្សាហ៍សុវត្ថិភាពជាតិ ។

**មាត្រា ២៩.- ទណ្ឌកម្មខាងព្រហ្មទណ្ឌ**

ដោយពុំទាន់គិតដល់បទល្មើសទាំងឡាយដែលមានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត :

-បុគ្គលណាដែលបដិសេធការផ្តល់ព័ត៌មានដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងស្ថាប័នត្រួតពិនិត្យ ដូចមានចែងក្នុងមាត្រា ៦ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ថ្ងៃ ដល់ ១ ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយសែនរៀល (១០០.០០០ រៀល) ដល់មួយលានរៀល (១.០០០.០០០ រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ ។

-បុគ្គលណាដែលមិនបានធ្វើរបាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ ឬ ប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា ១២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និង ផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល)ដល់ប្រាំលានរៀល (៥.០០០.០០០ រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ ។

-បុគ្គលណាដែលមានកាតព្វកិច្ចផ្តល់ព័ត៌មាន ឬ បញ្ជូនរបាយការណ៍ដូចមានចែងនៅក្នុងមាត្រា ១៣ ឬ បុគ្គលណាដែលបានដឹងរឿង ហើយផ្តល់ព័ត៌មាន ឬ របាយការណ៍ល្មើសនឹងបទប្បញ្ញត្តិនៃការហាមឃាត់ការផ្តល់ព័ត៌មាន ដូចមានចែងក្នុងមាត្រា ១៥ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ដល់ប្រាំលានរៀល (៥.០០០.០០០ រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ ។

-បុគ្គលណាដែលបានរំលោភកាតព្វកិច្ចរក្សាការសម្ងាត់ ដូចមានចែងក្នុងមាត្រា ២៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ដល់ប្រាំលានរៀល (៥.០០០.០០០ រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៣០.- ការឃាត់ទុកនិងរឹបអូសទ្រព្យសម្បត្តិ**

ក្នុងករណីមានការចោទប្រកាន់អំពីបទល្មើសសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌនោះ ទ្រព្យសម្បត្តិទាំងឡាយដែលពាក់ព័ន្ធ ឬ សង្ស័យថាពាក់ព័ន្ធនឹងបទល្មើស អាចត្រូវបានឃាត់ទុកមិនឱ្យមានចលនាផ្ទេរប្តូរ រហូតដល់មានការសម្រេចជាស្ថាពរពីតុលាការ ។

ក្នុងករណីតុលាការបានសម្រេចផ្តន្ទាទោសអំពីបទល្មើសសំអាតប្រាក់ ឬ ហិរញ្ញប្បទានភេរវកម្មរួចហើយ ទ្រព្យសម្បត្តិទាំងនោះត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

ស្ថាប័នត្រួតពិនិត្យ ត្រូវដាក់ចេញនូវបទប្បញ្ញត្តិ បទបញ្ជា និង សេចក្តីណែនាំសម្រាប់ការអនុវត្តច្បាប់នេះ ជាពិសេសចំពោះ :

-ការសម្របសម្រួលព័ត៌មាន ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដើម្បីស្រុះស្រួលគ្នាអំពីវិធានការទាំងឡាយ ដែលត្រូវប្រកាន់យកក្នុងការដាក់ទណ្ឌកម្មខាងវិន័យ ឬការបញ្ជូនទៅតុលាការចំពោះបទល្មើសទាំងឡាយដែលបានកើតឡើង

-ការសម្របសម្រួលរវាងស្ថាប័នត្រួតពិនិត្យផងគ្នា ដើម្បីដាក់ចេញបទប្បញ្ញត្តិ បទបញ្ជា និង សេចក្តីណែនាំដើម្បីអនុវត្តច្បាប់នេះ

-ការចេញបទបញ្ជា និង សេចក្តីណែនាំ ដើម្បីកំណត់តួនាទី និងភារកិច្ច និងសម្រាប់ការពារមន្ត្រី បុគ្គលិក ដែលបំពេញការងារដោយសុចរិតនៅក្នុងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ការរក្សាការសម្ងាត់នៃព័ត៌មាន និងវិធាននៃការបើកចំហព័ត៌មាន ។

ស្ថាប័នត្រួតពិនិត្យ ត្រូវសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ណែនាំបុគ្គលរាយការណ៍ក្នុងការរៀបចំបង្កើតនូវកម្មវិធីទប់ស្កាត់ការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មស្របតាមមាត្រា ១៦ នៃច្បាប់នេះ និងរៀបចំដាក់ចេញនូវគំរូរបាយការណ៍នានាឱ្យស្របតាមរូបភាព និង ចរិតលក្ខណៈនៃបុគ្គលរាយការណ៍ទាំងនេះ ។

បទបញ្ជា និង សេចក្តីណែនាំដែលចេញដោយស្ថាប័នត្រួតពិនិត្យក្រោមច្បាប់នេះ អាចកែប្រែ ឬ ធ្វើវិសោធនកម្មក្នុងកាលៈទេសៈសមស្រប ឬ នៅពេលដែលមានការចាំបាច់ ។

LE MINISTRE DU PALAIS ROYAL

**មាត្រា ៣២.-**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣.ល.០៧០៦.២៦៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខៈ ៧៥៥ ច.ល

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] កេន

4/24